**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**នាយកដ្ឋាននីតិកម្ម**

## ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំនាយកដ្ឋាននីតិកម្មក្រសួងការពារជាតិ ព្រមទាំងនាយ-ទាហាន នាយទាហានរង និងពលទាហានទាំងអស់បានតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះព្រឹត្តិការណ៍ដ៏មានសារសំខាន់ជាអាយុជីវិតរបស់ប្រទេសជាតិពាក់ព័ន្ធទៅនឹងសវនាការកាត់ទោស«រំលាយគណបក្សសង្គ្រោះជាតិ» របស់តុលាការកំពូលនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ យើងខ្ញុំសូមគាំទ្រទាំងស្រុងនិងយ៉ាងពេញទំហឹងចំពោះសាលដីការស្ថាពរដែលបាន«រំលាយគណបក្សសង្គ្រោះជាតិ» គឺពិតជាស័ក្តិសមទៅនឹងទោសកំហុសនៃទង្វើក្បត់ជាតិរបស់គណបក្សមួយនេះដែលបានប្រព្រឹត្តកន្លងមក។

យើងខ្ញុំទាំងអស់គ្នាសូមគាំទ្រចំពោះវិធានការច្បាប់របស់តុលាការ និងសូមគោរពអនុវត្តតាមបទបញ្ជាដ៏ម៉ឺងម៉ាត់របស់ក្រសួងការពារជាតិ ជាពិសេសត្រៀមអនុវត្តបទបញ្ជាគ្រប់កាលៈទេសៈ ចំពោះវិធានការបន្តដែលដាក់ចេញដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការទប់ស្កាត់ឧបាយកលពិសពុលនៃបដិវត្តន៍ពណ៌នៅកម្ពុជា។

សូមប្តេជ្ញារួមចំណែកថែរក្សា ការពារសន្តិសុខ សន្តិភាព និងការអភិវឌ្ឍន៍នៅកម្ពុជា ប្រឆាំងដាច់ខាតរាល់ឧបាយកលរបស់ក្រុមអ្នកនយោបាយនិងជនអគតិមួយចំនួនដែលឃុបឃិតនិងបម្រើផលប្រយោជន៍បរទេស។ ប្តេជ្ញាការពារបូរណភាពទឹកដីនៃកម្ពុជា ប្រឆាំងនឹងការជ្រៀតជ្រែកទាំងឡាយរបស់បរទេស។ ប្តេជ្ញាគាំទ្រការអនុវត្តវិធានការច្បាប់ និងការគោរពច្បាប់និងសង្គមដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំនាយកដ្ឋាននីតិកម្មក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់សូមគាំទ្រនិងសម្តែងនូវភក្តីភាពយ៉ាងស្មោះស្ម័គ្រចំពោះថ្នាក់ដឹកនាំក្រសួងការពារជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខដឹកនាំដ៏ឈ្លាសវៃដែលតែងតែបានបូជា កម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុង្គឧត្តមប្រកបដោយមនសិការទទួលខុសត្រូវខ្ពស់ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។

យើងខ្ញុំទាំងអស់គ្នាសូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើក្បត់របស់គណបក្សសង្គ្រោះជាតិ និងថ្នាក់ដឹកនាំ ក៏ដូចជាជនអគតិមួយចំនួនដែលបានឃុបឃិតជាមួយបរទេស ព្រមទាំងប្រឆាំងដាច់ខាតរាល់ឧបាយកលបដិវត្តន៍ពណ៌មិនឲ្យនាំមកនូវសង្គ្រាមវិនាសកម្មនិងគ្រោះមហន្តរាយជាថ្មីម្តងទៀតនៅកម្ពុជានោះឡើយ។

សូមគាំទ្រឲ្យមានការចាត់វិធានការផ្លូវច្បាប់ជាបន្តបន្ទាប់ទៀតឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋក្នុងគោលបំណងថែរក្សាសន្តិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ និងដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧

**នាយក**

ឧត្តមសេនីយ៍ឯក ម៉ម សុផាត



Scanned by CamScanner